# ព័ត៌មានស្ដីពីការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ លើកទី៣(ដូសជំរុញ)
# សម្រាប់ជនបរទេសដែលរស់នៅក្នុងប្រទេសកូរ៉េ(អាយុ១២~១៧ឆ្នាំ)

ចំនួនករណីដែលបានឆ្លងកំពុងកើនឡើង ក្នុងចំណោមយុវជន(អាយុពី១២~១៧ឆ្នាំ) ដោយពេលវេលាកន្លងផុតបន្ទាប់ពីការចាក់វ៉ាក់សាំងបឋមហើយចំនួនករណីធ្ងន់ធ្ងរ និងការស្លាប់នៅតែបន្ត។ អាស្រ័យហេតុនេះ ដើម្បីការពារយុវជនពីការធ្ងន់ធ្ងរ និងការស្លាប់ដោយសារការឆ្លងជំងឺកូវីដ-១៩ សូមជម្រាបជូនថា ការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩លើកទី៣ នឹងត្រូវចាក់ជូនជនបរទេសដែលមានអាយុពី១២~១៧ឆ្នាំ ដែលកំពុងរស់នៅក្នុងប្រទេសកូរ៉េ ដូចខាងក្រោម។

## ■ គោលដៅចាក់វ៉ាក់សាំង

○ ក្នុងចំណោមយុវជន អាយុពី១២~១៧ឆ្នាំ ដែលពេលវេលាកន្លងផុត៣ខែ បន្ទាប់ពីបានបញ្ចប់ការចាក់វ៉ាក់សាំងមូលដ្ឋាន នៅក្នុងស្រុក ឬនៅបរទេស សម្រាប់ក្រុមដែលមានហានិភ័យខ្ពស់ ដែលគ្រោះថ្នាក់ធ្ងន់ គឺត្រូវបានណែនាំឱ្យចាក់វ៉ាក់សាំងយ៉ាងសកម្ម។

※ ករណីយុវជន(អាយុពី១២~១៧ឆ្នាំ) មានប្រវត្តិនៃការឆ្លងជំងឺកូវីដ-១៩ គឺដូចមនុស្សពេញវ័យដែរ មិនត្រូវបានណែនាំឱ្យចាក់វ៉ាក់សាំងដូសទី៣។

## ■ ប្រភេទវ៉ាក់សាំង, រយៈពេលចាក់

○ ការចាក់វ៉ាក់សាំងដូសទី៣ សម្រាប់យុវជនគឺ ចាក់វ៉ាក់សាំងហ្វាយសឺរ(Pfizer)។

○ ក្នុងចំណោមយុវជន អាយុពី១២~១៧ឆ្នាំ កន្លងផុត៣ខែ(៩០ថ្ងៃ) បន្ទាប់ពីបញ្ចប់ការចាក់វ៉ាក់សាំងជាមូលដ្ឋាន នឹងអាចទទួលការចាក់វ៉ាក់សាំងដូសទី៣បាន។ ប៉ុន្តែ, អ្នកដែលមានប្រព័ន្ធភាពស៊ាំខ្សោយ* គួរចាក់វ៉ាក់សាំងក្រោយរយៈពេល២ខែ។

* អ្នកដែលមានប្រព័ន្ធភាពស៊ាំខ្សោយគឺ អាចទទួលលិខិត បញ្ជាក់ការព្យាលបាលឬវេជ្ជបញ្ជារបស់វេជ្ជបណ្ឌិត ពីស្ថាប័នវេជ្ជសាស្ត្របាន ហើយអ្នកបង្ហាញលិខិតនោះទៅមណ្ឌលសុខភាពក្នុងតំបន់ ហើយអ្នកអាចកែតម្រូវរយៈពេលចាក់វ៉ាកសាំងបាន។

## ■ កាលវិភាគ និងទីតាំងចាក់វ៉ាក់សាំង

○ **ការកក់ទុកជាមុន** និង**ការចាក់ដោយមិនកក់ទុកមុន** គឺចាប់ពី(ច័ន្ទ)**ថ្ងៃទី១៤ ខែមីនា** និង**ការកក់ចាក់** ចាប់ពី(ច័ន្ទ)**ថ្ងៃទី២១ ខែមីនា**។

○ ទីកន្លែងចាក់ថ្នាំបង្ការគឺ អ្នកអាចទទួលការចាក់ថ្នាំបង្ការនៅ**ស្ថាប័នវេជ្ជសាស្ត្រ, មណ្ឌលសុខភាព ឬមជ្ឈមណ្ឌលចាក់ថ្នាំបង្ការ** ដែលគ្រប់គ្រងការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ ដោយមិនគិតថាអ្នកមានធានារ៉ាប់រងសុខភាព ឬអត់នោះទេ។

## ■ វិធីសាស្ត្រនៃការកក់

១. ជនបរទេសដែលមានអាយុពី១២~១៧ឆ្នាំ ដែលបានបញ្ចប់ការចាក់វ៉ាក់សាំងមូលដ្ឋាន នៅក្នុងប្រទេសកូរ៉េ

១) ជនដែលបានចុះឈ្មោះជាជនបរទេស: អាចធ្វើការកក់តាមរយៈអនឡាញ ឬទូរស័ព្ទ ដូចគ្នានឹងការចាក់វ៉ាក់សាំងជាមូលដ្ឋានដែរ។

① ការកក់តាមរយៈអនឡាញ: សាមីខ្លួននិងអ្នកកក់ជំនួស អាចចូលទៅប្រព័ន្ធកក់ទុកមុននៃការចាក់វ៉ាក់សាំងកូវីដ១៩(https://ncvr.kdca.go.kr)

② ការកក់ទុកតាមទូរស័ព្ទ: អាណាព្យាបាលកក់ជំនួស តាមរយៈមជ្ឈមណ្ឌលគ្រប់គ្រងនិងបង្ការជំងឺកូរ៉េ(☏១៣៣៩) ឬរដ្ឋាភិបាលក្នុងតំបន់

③ ការចាក់ដោយមិនកក់ទុកមុន: ចាក់ភ្លាមៗនៅថ្ងៃដែលចង់ចាក់ បន្ទាប់ពីការចុះឈ្មោះក្នុងបញ្ជីបឋមនៃស្ថាប័នវេជ្ជសាស្ត្រ (បញ្ជាក់ដោយខ្សែទូរស័ព្ទ)

* ការកក់វ៉ាក់សាំងដែលនៅសេសសល់តាមរយៈ SNS គឺអាចប្រើបានសម្រាប់តែអ្នកដែលមានអាយុចាប់ពី១៤ ឆ្នាំឡើងទៅប៉ុណ្ណោះ

○ ជនដែលមិនបានចុះឈ្មោះជាជនបរទេស(រួមទាំងជនបរទេសខុសច្បាប់): បន្ទាប់ពីទទួលបានលេខគ្រប់គ្រង បណ្ដោះអាសន្នពីមណ្ឌលសុខភាព អ្នកអាចកក់តាមទូរស័ព្ទ ឬទៅកក់ផ្ទាល់នៅស្ថាប័នសម្រាប់ចាក់វ៉ាក់សាំង(ស្ថាប័នវេជ្ជសាស្ត្រ ឬមណ្ឌលសុខភាព)

## ■ ជនបរទេសដែលបានចាក់វ៉ាក់សាំងមូលដ្ឋាននៅបរទេស (រួមទាំងជនបរទេសដែលស្នាក់នៅរយៈពេលខ្លី ក្រោម៩០ថ្ងៃ)

អ្នកអាចធ្វើការកក់ទុក ដោយទៅមណ្ឌលសុខភាពផ្ទាល់ ដែលនៅជិតដោយភ្ជាប់ជាមួយអត្តសញ្ញាណប័ណ្ណរបស់អ្នក បន្ទាប់ពីទទួលបានលេខគ្រប់គ្រងបណ្ដោះអាសន្ន និងចុះឈ្មោះប្រវត្តិនៃការចាក់វ៉ាក់សាំងនៅបរទេសរបស់អ្នកហើយ បន្ទាប់មកធ្វើការកក់ទុកតាមទូរស័ព្ទ ឬទៅកក់ផ្ទាល់នៅស្ថាប័នសម្រាប់ចាក់វ៉ាក់សាំង(ស្ថាប័នវេជ្ជសាស្ត្រ ឬមណ្ឌលសុខភាព)។

* នៅពេលចេញលេខគ្រប់គ្រងបណ្ដោះអាសន្ន មិនត្រូវបានទាមទារឱ្យបង្ហាញអត្តសញ្ញាណ ដូចជាលិខិតឆ្លងដែន, ប័ណ្ណចុះឈ្មោះជនបរទេសទេ។

ករណីជាយុវជន ចាំបាច់ត្រូវអមដំណើរជាមួយអាណាព្យាបាល ឬអ្នកតំណាងផ្លូវច្បាប់ ដើម្បីសុវត្ថិភាពនៃការចាក់វ៉ាក់សាំង និងតាមដានប្រតិកម្មមិនល្អ។ (អាណាព្យាបាល គឺទៅជាមួយកុមារ បន្ទាប់ពីផ្ទៀងផ្ទាត់អត្តសញ្ញាណរួច បំពេញទម្រង់បែបបទរោគវិនិច្ឆ័យជាមុន នៅស្ថាប័នផ្ដល់ថ្នាំបង្ការ)
* ករណីអាណាព្យាបាល មិនបានអមដំណើរជាមួយ សូមរៀបចំទម្រង់យល់ព្រមចាក់ថ្នាំបង្ការ និងទម្រង់ពិនិត្យបឋមជាមុន ហើយអ្នកដែលត្រូវចាក់ថ្នាំបង្ការ ប្រគល់ជូនស្ថាប័នវេជ្ជសាស្ត្រ។

## ※ សេចក្ដីយោង

- ព័ត៌មានដែលពាក់ព័ន្ធនឹងអត្តសញ្ញាណ គឺត្រូវបានប្រើសម្រាប់គោលបំណងចាក់វ៉ាក់សាំងតែប៉ុណ្ណោះ និងយោងតាមប្រព័ន្ធលើកលែងកាតព្វកិច្ចជូនដំណឹងគឺនឹងមិនត្រូវបានជូនដំណឹងអំពីស្នាក់នៅដោយខុសច្បាប់ផ្សេងៗទៅការិយាល័យអន្តោប្រវេសន៍·ជនបរទេសទេ។
- សម្រាប់ព័ត៌មានបន្ថែម សូមមើលនៅលើគេហទំព័ររបស់មជ្ឈមណ្ឌលគ្រប់គ្រង និងបង្ការជំងឺកូរ៉េ(KCDC) សម្រាប់ការចាក់វ៉ាក់សាំងកូវីដ១៩(https://ncv.kdca.go.kr)។